## សារពិសេសមកពីក្រសួងអប់រំ ឡុងប៊ីច

ជម្រាបជូនសហគមន៍សាលារៀន ឡុងប៊ីច,

រួមគ្នា គឺយើងបានទទួលការទ្រាំជាមួយបញ្ហាច្រើនចំណែកណាស់ក្នុងរយៈពេលដ៏សែនលំបាកនៅតាមសាលារៀន និង ប្រទេសជាតិរបស់យើង ។ ទឹកចិត្តតស៊ូ និង ការប្តេជ្ញាចិត្តរបស់លោកអ្នកសម្រាប់គាំទ្រមកលើសិស្សរបស់យើង គឺបានផ្តល់ជាសេចក្តីសង្ឃឹម និង ទឹកចិត្តប្រឹងប្រែងខ្ពស់ នៅពេលយើងសម្លឹងទៅមុខសម្រាប់ទទួលយកឱកាសសព្វយ៉ាងក្នុងឆ្នាំថ្មី ។

តើនរណាអាចស្មានទុកមុនបានថា កាលពីខែមិនា ឆ្នាំ2020 ជាពេល ដែលយើងបានបិទសាលារៀនលើកដំបូង ក៏ស្រាប់តែដល់ចំនួន 20 ខែ ជាបន្ទាប់មក យើងនៅតែជួបជាមួយជម្ងឺរាលដាលពេញពិភពលោកដដែល? ចាប់តាំងពីថ្ងៃដំបូង ដែលសាលារៀនបិទទ្វារ គឺយើងបានចំណាំឃើញអំពីជម្ងឺរាលដាល ដែលបង្កជាបញ្ហាស្មុគស្មាញមកលើផ្នែកសេដ្ឋកិច្ច និង អារម្មណ៍នៅតាមសហគមន៍របស់យើង ។

ទោះជាយ៉ាងណាក្តី យើងនៅតែប្រឹងតស៊ូ ដើម្បីរក្សាការបង្ហាត់ និង ការរៀនឱ្យនៅតែមានជាបន្ត និង បង្កើនផ្នែកសមធម៌ឱ្យបានកាន់តែប្រសើរ និង កាន់តែស្មើគ្នាសម្រាប់ពេលជាយូរឆ្នាំទៅមុខដល់សិស្សកាន់តែច្រើននាក់ ។

សិស្ស ក្រុមគ្រួសារ និង បុគ្គលិករបស់យើងសមនឹងទទួលការសរសើរ ដោយចេះធ្វើការបត់បែនស្របតាមកាលៈទេសៈមិនធ្លាប់មានពីមុនមក ។ ការយកចិត្តទុកដាក់របស់ពួកគេសម្រាប់គោរពតាមក្បួនអនាម័យ និង សុវត្ថិភាព ដែលរាប់បញ្ចូលផងទាំងការចាក់ថ្នាំ ការពាក់គម្របមុខ ការធ្វើ តេស្ត កូវីដ និង ការពិនិត្យសុខភាពផ្ទាល់ខ្លួន ការឃាត់ខ្លួនទុកនៅផ្ទះ បើសិនចាំបាច់ ការជូតសំអាតដៃ និង ការធ្វើតាមអ្វីជាបន្ថែមទៀត គឺបានផ្តល់ជាឱកាសសម្រាប់យើងបើកការទទួលស្វាគមន៍សិស្សភាគច្រើនរបស់យើង ដែលមានចំនួន 69,000 នាក់ ឱ្យត្រឡប់ចូលសាលារៀនវិញ និង នៅតែបើកសាលារៀនសម្រាប់កន្លែងចូលរៀនជាដដែល ។

សារៈសំខាន់អំពីការចូលរៀនក្នុងថ្នាក់ផ្ទាល់ គឺមិនអាចនិយាយទាំងបំផ្លើសបានទេ ។ នៅពេលដែលគ្រូបង្រៀន និង យើងរាល់គ្នានៅក្នុងសហគមន៍សាលារៀនបានប្រឹងប្រែងយ៉ាងក្លាហានសម្រាប់ផ្តល់ជាជំនួយរៀន អនឡាញ ក្នុងរយៈពេលជម្ងឺរាលដាលចាប់ផ្តើមកើតភ្លាម គឺបទពិសោធន៍នោះឯងបានធ្វើការបញ្ជាក់មកលើអ្វីដែលយើងបានដឹងក្នុងវិញ្ញាណស្រាប់មកហើយតាំងពីពេលនោះមក ។ មន្តអាគមកើតឡើងនៅតាមបន្ទប់រៀន ហើយសិស្សភាគច្រើនត្រូវការការនិយាយឆ្លងឆ្លើយទំនាក់ទំនង និង ការជួបជុំទល់មុខគ្នា ដែលមានតែការរៀននៅក្នុងថ្នាក់ផ្ទាល់ដូចពីពេលមុនៗមកប៉ុណ្ណោះ ទើបអាចជួយបាន ។ និយាយឱ្យចំ គឺមានសិស្សភាគច្រើនកំពុងតែជួបបញ្ហានៅឡើយ ប៉ុន្តែ យើងក៏បានចំណាំឃើញរួចមកហើយដែរអំពីឥទ្ធិពល ដែលនាំមកជាលទ្ធផលដ៏ល្អសម្រាប់សិស្សនៅពេលបានត្រឡប់ចូលសាលារៀនវិញ ។

សូម្បីតែយើងនៅតែបន្តការលៃលកដោះស្រាយជាមួយបញ្ហាជម្ងឺរាលដាលនេះក៏ដោយ ក៏គណៈកម្មការនាយកផ្នែកសិក្សាធិការ និង ក្រុមដឹកនាំរបស់យើងកំពុងតែធ្វើការសម្លឹងទៅកាន់អនាគត និង ការរៀបចំសហគមន៍ បន្ទាប់ពីជម្ងឺរាលដាលទទួលវិនាសផុតទៅ ។ នៅដើមខែនេះ គណៈកម្មការសាលារៀនបានបោះឆ្នោតទទួលស្គាល់មកលើច្បាប់ផ្នែក ឧត្តមភាព និង សមធម៌ ដោយធ្វើការអះអាងទាំងសេចក្តីក្លាហានរបស់ពួកគេសម្រាប់គាំទ្រទៅកាន់សិស្សគ្រប់រូបនៅតាមក្រសួងអប់រំ ឡុងប៊ីច របស់យើង ។ នៅក្នុង គម្រោងបង្កើនល្បឿនសិក្សា និង ផ្តល់ជំនួយទូទៅ របស់យើង គឺបានរាប់បញ្ចូលផងទាំងការជួលបុគ្គលិកមានសារតាំងយ៉ាងត្រឹមត្រូវមកធ្វើការដែលមានដូចជា ... គ្រូបង្រៀន អ្នកផ្តល់ឱវាទ និង សូហ្សាល់ វើគ័រ ដើម្បីបញ្ជាក់ថា សិស្សរបស់យើងពិតជាមានជំនួយស្របតាមសេចក្តីត្រូវការមែន ដើម្បីជួយពួកគេឱ្យមានសមត្ថភាពកាន់តែរឹងមាំ និង ប្រសើរឡើងពីគ្រាឆ្លងកាត់ជម្ងឺរាលដាល ។

សូម្បីតែកំពុងស្ថិតនៅក្នុងគ្រាដ៏សែនលំបាកក៏ដោយ ក៏ក្រសួងអប់រំ LBUSD នៅតែបន្តការជាប់ឈ្មោះក្នុងនាមជា ប្រព័ន្ធសាលារៀននាំមុខ នៅតាមកម្រិតជាតិ និង រដ្ឋ ដោយយោងតាមការដកស្រង់ព័ត៌មានជាច្រើនចំណែក ដែលយើងកំពុងលើកបង្ហាញជូនក្នុងសប្តាហ៍នេះនៅតាម គេហទំព័រ និង បណ្តាញផ្សព្វផ្សាយសង្គមរបស់យើង ។ លើសជាងអ្វីផ្សេងៗទៅទៀតក្នុងរយៈពេលឥឡូវ គឺយើងមិនអាចទទួលយកការជាប់ឈ្មោះជាកម្រិតនេះយ៉ាងស្រាលៗបានទេ ហើយយើងក៏មិនអាចបំភ្លេចបានដែរអំពីការប្រឹងប្រែងរួមជាក្រុម ដែលនាំបង្កើនជាលទ្ធផលជោគជ័យដូច្នេះ ។

យើងនៅទីនេះសម្រាប់ទទួលស្វាគមន៍ឱកាសសព្វយ៉ាងក្នុងឆ្នាំថ្មី និង ធ្វើការបង្រួមគ្នាសម្រាប់ដំណោះស្រាយមកលើបញ្ហារបស់យើង រួមទាំងសេចក្តីសង្ឃឹមទុករបស់យើងផងសម្រាប់សិស្សជំនាន់ក្រោយ ។

ដោយសេចក្តីអំណរគុណយ៉ាងជ្រៅជ្រះ,

-Jill

Jill A. Baker, Ed. D.
អគ្គនាយកសាលារៀន